## ចូរអោយពត៌មាននេះទៅលោកវេជ្ជបណ្ឌិតរបស់លោកអ្នក។

សូមជូនចំពោះ លោកវេជ្ជបណ្ឌិត,

អ្នកជម្ងឺរបស់លោកវេជ្ជបណ្ឌិតគឺនៅក្នុងក្រុមមនុស្សដែលអាចកើតរោគរលាកថ្លើម B ។ សូមមេត្តាធ្វើតេស្ត ហើយនឹងចាក់ថ្នាំបង្ការរោគរលាកថ្លើម B ឲ្យអ្នកជម្ងឺរបស់លោក។

មធ្យោបាយសំរាប់ពិនិត្យដូចតទៅនេះប្រហែលជាអាចយកមកប្រើដើម្បីស្ទង់មើលសុខភាពរបស់អ្នកជម្ងឺពីស្ថានការណ៍រោគរលាកថ្លើម B:

- សារធាតុដែលបណ្ដាលឲ្យកើតរោគរលាកថ្លើម B (hepatitis B surface antigen (HBsAg) នឹង
- បណ្ដូលអង្គបដិបក្ខរោគរលាកថ្លើម B (hepatitis B core antibody (anti-HBc)

ឬវិធីផ្សេងទៀត:

- សារធាតុដែលបណ្ដាលឲ្យកើតរោគរលាកថ្លើម B (hepatitis B surface antigen (HBsAg) និង
- ផ្ទៃអង្គបដិបក្ខរោគរលាកថ្លើម B (hepatitis B surface antibody (anti-HBs)

សូមអោយអ្នកជម្ងឺនូវក្រដាសចម្លងលទ្ធផលតេស្ត ក៏ដូចក្រដាសបញ្ជីកត់នៃការចាក់ថ្នាំផងដែរ។

មនុស្សដែលទំនងមានរោគរលាកថ្លើម B គឺមកពីទ្វីបអាហ្វ្រិក, អាស៊ី, អឺរ៉ុបខាងកើត, មជ្ឈិមបូព៌ា (Middle East), ភូមិភាគជិតខាងកើត (Near East), ទន្លេអាម៉ាហ្សូន (Amazon Basin), កោះនៅតាមមហាសមុទ្រ ប៉ាស៊ីហ្វិក (Pacific Islands), និងជនបទនៅរដ្ឋអាឡាស្កា (Alaska)។

ដូចអ្នកដឹងស្រាប់ហើយ រោគរលាកថ្លើម B អាចបណ្ដាលអោយថ្លើមឈប់ដើរ, មានកើតមហារីកថ្លើម ហើយនឹងស្លាប់។

បើសិនជា លោកអ្នកចង់បានពត៌មានបន្ថែមពីក្រសួងសហពលកម្មការពាររោគរលាក ថ្លើម B (Hepatitis B Coalition) ចូរទាក់ទងមកយើង។ យើងមានប្រភពជំនួយជាច្រើនសំរាប់គ្រូពេទ្យ។ យើងក៏មានបោះពុម្ពព្រឹត្តិប័ត្រដោយមិនគិតលុយសំរាប់វេជ្ជបណ្ឌិត ហើយនឹងក្រសួងសុខភាពអំពីរោគរលាកថ្លើម B ក៏ដូចការចាក់ថ្នាំការពារក្មេងនឹងមនុស្សចាស់ផងដែរ។

ហត្ថលេខា,

Deborah L. Wexler

Deborah L. Wexler, M.D.
នាយកប្រតិបត្តិ, Hepatitis B Coalition
1573 Selby Ave., #234, St. Paul, MN 55104

---

**ដើម្បីស្វែងរកស្ថានការណ៍រោគរលាកថ្លើម B ចូរយកកូនសៀវភៅស្ដើងនេះទៅឲ្យលោកវេជ្ជបណ្ឌិតរបស់លោកអ្នក ហើយសួរសុំអោយពិនិត្យមើលឈាមរបស់លោកអ្នក។**

---

Hepatitis B Coalition
Immunization Action Coalition
1573 Selby Avenue, Suite 234
St. Paul, MN 55104
651-647-9009
www.immunize.org

ក្រសួងសហពលកម្មការពាររោគរលាកថ្លើម B ខិតខំផ្សាយអោយមានការចាក់ថ្នាំការពាររោគរលាកថ្លើម B ដល់កូនខ្ចីទាំងអស់ ហើយនឹងក្មេងជំទង់; ការពិនិត្យមើលរោគរលាកថ្លើម B សំរាប់ស្ត្រីមានផ្ទៃពោះ; ធ្វើតេស្តហើយនឹងចាក់ថ្នាំការពារសំរាប់ក្រុមមនុស្សដែលទំនងមានរោគនេះជាងគេ; ការអប់រំហើយនិងការព្យាបាលមនុស្សមានមេរោគរលាកថ្លើម B ។ ក្រសួងសហពលកម្មការពាររោគរលាកថ្លើម B គឺជាកម្មវិធីនៃក្រសួងសហពលកម្មការពារការចាក់ថ្នាំបង្ការរោគ (Immunization Action Coalition)។

រូបគំនូរបានបោះពុម្ពម្ដងទៀតដោយមានការអនុញ្ញាតពី *Hands Around the World* ដោយ Susan Milord ©1992 Williamson Publishing Co., Charlotte, VT.

Item # P4170-03 Cambodian (5/95)

# បើសិនលោកអ្នក, ឪពុកម្ដាយរបស់លោកអ្នក, ឬកូនរបស់លោកអ្នកបានកើតនៅទីកន្លែងដូចមានតទៅនេះ...

ប្រទេសអាហ្វហ្គានីស្ថាន, ទ្វីបអាហ្វ្រិក, ជនបទរដ្ឋអាឡាស្កា, អាបានីញ៉ា, បែងក្លាដែស, ប៉ោស្នៀនឹងហិកស៊ីកូវីណា, ប៊ុលហ្គារី, ភូមា, កម្ពុជា, ចិន, ទ្វីបអឺរ៉ុបខាងកើត, ហៃទី, ហាវ៉ៃ, ឥណ្ឌា, ឥណ្ឌូនេស៊ី, អៀរ៉ង់, អៀរ៉ាក់, កូរ៉េ, លាវ, ម៉ាឡេយ្សូ, មជ្ឈិមបូព៌ា (Middle East), ប៉ាគីស្ថាន, កោះនៅមហាសមុទ្រប៉ាស៊ីហ្វិក, ហ្វីលីពីន, រូម៉ានី, អតីតសហភាពសូវៀត, ទន្លេអាម៉ាហ្សូននៅអាមេរិកខាងត្បូង, ស៊ីរីលង្កា, ស៊ីរី, តៃវ៉ាន់, ថៃ, ឬប្រទេសវៀតណាម



## ...អោយកូនសៀវភៅស្ដើងនេះទៅលោកវេជ្ជបណ្ឌិត លោកអ្នក ហើយសួរឲ្យពិនិត្យរកមើលនូវស្ថានការណ៍នៃរោគរលាកថ្លើម B របស់លោកអ្នក។

## អ្វីទៅជារោគរលាកថ្លើម B នោះ?

រោគរលាកថ្លើម B គឺរោគថ្លើមធ្ងន់ធ្ងរមួយដែលកើតឡើងដោយមេរោគ។ មេរោគនេះអាចចូលទៅតាមសសៃឈាម ហើយប្រឆាំងនិងថ្លើម។ រោគរលាកថ្លើម B គឺច្រើនមានកើតដល់មនុស្សដែលរស់នៅឬកើតក្នុងតំបន់នៃពិភពលោកដែលមានចុះឈ្មោះនៅខាងលើគ្របសៀវភៅនេះ។ បើសិនជាលោកអ្នកស្គាល់អ្នកណាមានរោគរលាកថ្លើម B មនុស្សនោះមានគ្រោះថ្នាក់ច្រើនដែលបណ្តាលឲ្យថ្លើមឈប់ដើរ ឬកើតរោគមហារីកថ្លើម។

## តើលោកអ្នកដឹងដោយរបៀបណា បើសិនជាលោកអ្នកមានរោគរលាកថ្លើម B នោះ?

វាជាការសំខាន់ណាស់ក្នុងការដឹងថា លោកអ្នកមានរោគរលាកថ្លើម B នោះ។ មានមនុស្សរាប់លាននាក់នៅជុំវិញពិភពលោកឆ្លងមេរោគនេះ។ ភាគច្រើនមនុស្សដែលគ្មានអាការៈរោគ ប៉ុន្តែការមានរោគថ្លើមធ្ងន់ធ្ងរ ប្រហែលជាអាចមានកើតឡើង ពីរបីឆ្នាំក្រោយពីមានរោគដោយមិនដឹងនេះ។ មធ្យោបាយតែមួយគត់ដើម្បីឲ្យដឹងពីស្ថានការណ៍រោគរលាកថ្លើម B គឺការធ្វើតេស្តឈាមរបស់លោកអ្នក។ តេស្តឈាមនេះនឹងប្រាប់ថាស្ថានការណ៍រោគរលាកថ្លើម B លោកអ្នកស្ថិតនៅក្នុងចំណោមមួយនៃ:

**ការងាយឆាប់:** បើសិនជាលោកអ្នកងាយឆាប់ឆ្លងរោគរលាកថ្លើម B មានន័យថា លោកអ្នកមិនដែលធ្លាប់មានរោគនោះឡើយ។ លោកអ្នកប្រហែលជាអាចមានរោគនេះនៅអនាគត។ <u>បើសិនជាលោកអ្នកងាយឆាប់ឆ្លងរោគនេះ លោកអ្នកគួរតែចាក់ថ្នាំការពារខ្លួនពីរោគនេះភ្លាម។</u>

---

បើសិនជាលោកអ្នកមានការងាយឆាប់ឆ្លងរោគរលាកថ្លើម B ការចាក់ថ្នាំបីលើកនិងអាចការពារលោកអ្នកបាន !

---

**ការចាក់ថ្នាំបង្ការ:** បើសិនជាលោកអ្នកអាចគេចរួចផុតពីរោគរលាកថ្លើម B លោកអ្នកបានមានរោគនេះកាលពីអតីតកន្លងរួចមកហើយ។ ខ្លួនរបស់លោកអ្នកអាចសម្លាប់មេរោគដែលធ្វើឲ្យមានរោគនេះ។ <u>លោកអ្នកមានសន្តិសុខការពារពីរោគរលាកថ្លើម B ហើយមិនអាចមានរោគនេះទៀតឡើយ។</u>

**អ្នកមានមេរោគ:** បើសិនជាលោកអ្នកមានរោគរលាកថ្លើម B គឺលោកអ្នកមានមេរោគនេះនៅក្នុងខ្លួន។ ជាទូទៅលោកអ្នកគ្មានអារម្មណ៍ឈឺថ្កាត់អ្វីឡើយ <u>ប៉ុន្តែលោកអ្នកអាចធ្វើឲ្យរោគនេះឆ្លងទៅមនុស្សដទៃទៀត។ លោកអ្នកត្រូវការមានការព្យាបាលជានិច្ចហើយមកពិនិត្យធ្វើតេស្តទៀងទាត់ដើម្បីមើលនូវការរីកចំរើនរបស់ជម្ងឺថ្លើមធ្ងន់ធ្ងរនេះ។</u>

## តើខ្ញុំមានរោគរលាកថ្លើម B នេះដោយរបៀបណាដែរ?

មានរបៀបច្រើនណាស់ រោគរលាកថ្លើម B គឺឆ្លងដោយការប៉ះពាល់នឹងឈាមឬវត្ថុរាវក្នុងខ្លួនមនុស្ស។ មធ្យោបាយទូទៅខ្លះនៃការមានរោគរលាកថ្លើម B រួមចូល:

- ពីម្តាយទៅកូនង៉ានៅពេលកើតកូន
- សេពកាម
- ប៉ះពាល់ជាមួយនិងឈាមមនុស្សដទៃ
- ប្រើប្រាស់ដុសធ្មេញឬកាំបិតកោរពុកមាត់ចូលគ្នា
- ទំពារម្ហូបសំរាប់ឲ្យកូនង៉ាបរិភោគ
- ការខាំ
- ប្រើម្ជុលដែលមិនបានរម្ងាប់មេរោគសំរាប់ចោះត្រចៀក, ចាក់ថ្នាំញៀន, ម្ជុលវិទ្យាសាស្ត្រ ឬចារសាក់
- រស់នៅជាមួយមនុស្សណាម្នាក់ដែលមានរោគរលាកថ្លើម B ។

រោគរលាកថ្លើម B គឺមិនឆ្លងតាមការកណ្តាស់, ក្អក ឬដោយកាន់ដៃគ្នានោះឡើយ។

## តើមានថ្នាំព្យាបាលអោយជាស្បើយសំរាប់រោគរលាកថ្លើម B នេះទេ?

បើសិនជាមនុស្សណាម្នាក់មានឈឺថ្លើមដោយសាររោគរលាកថ្លើម B មានថ្នាំហៅថា interferon ដែលជួនកាលអាចជួយមនុស្សមានរោគនេះ។ ថ្នាំនេះអាចធ្វើឲ្យមានប្រតិកម្ម ហើយសំរាប់ប្រើនៅពេលធ្វើតេស្តមើលឈាមថ្លើមមនុស្សនោះបង្ហាញថ្លើមខូចខាតប៉ុណ្ណោះ។ ភាគច្រើនមនុស្សដែលមានរោគរលាកថ្លើម B មិនចាំបាច់ត្រូវការប្រើថ្នាំនេះទេ ហើយរស់នៅមានសុខភាពល្អធម្មតាទៀតផង។

បើសិនជាលោកអ្នកមានរោគរលាកថ្លើម B លោកអ្នកគួរតែសួរយោបល់វេជ្ជបណ្ឌិតឲ្យពិនិត្យរាងកាយ នឹងធ្វើតេស្តឈាមរៀងរាល់ឆ្នាំ ដើម្បីពិនិត្យមើលស្ថានការណ៍ថ្លើមរបស់លោកអ្នក ក៏ដូចការឆ្លុះពិនិត្យមើលឲ្យបានរកឃើញរោគមហារីកថ្លើមជាមុនទាន់ពេលវេលាផងដែរ។

អ្នកមានរោគរលាកថ្លើម B គួរតែជៀសវៀងពិសារសុរា ហើយនឹងធ្វើយ៉ាងណាឲ្យក្រុមសមាជិកគ្រួសារទាំងអស់ ហើយនឹងគូស្នេហាចាក់ថ្នាំការពាររោគនេះ។

អ្នកស្រាវជ្រាវបន្តការស្វែងរកការព្យាបាលបន្ថែមហើយព្យាបាលអោយជាស្បើយសំរាប់មនុស្សមានរោគរលាកថ្លើម B ។

## តើអោយខ្ញុំទៅកន្លែងណាដើម្បីធ្វើតេស្តនឹងចាក់ថ្នាំការពាររោគរលាកថ្លើម B?

សួរយោបល់វេជ្ជបណ្ឌិត។ បើសិនជាលោកអ្នកគ្មានការធានារ៉ាប់រង ឬក៏ក្រុមធានារ៉ាប់រងរបស់លោកអ្នកមិនធានាបង់ថ្លៃសំរាប់ធ្វើតេស្ត ឬចាក់ថ្នាំនេះទេ ក្រុមគ្រួសារលោកអ្នកប្រហែលជាអាចទទួលការធ្វើតេស្តនេះ ដោយមិនអស់លុយ ហើយចាក់ថ្នាំតាមក្រសួងសុខភាពក្រុង ឬខោនធី។ ចូរទូរស័ព្ទទៅក្រសួងសុខភាព ដើម្បីព័តមានបន្ថែម។